# Vacancy Announcement

FTB
ធនាគារពាណិជ្ជកម្មក្រៅប្រទេស នៃកម្ពុជា
Foreign Trade Bank of Cambodia

## ដំណឹងជ្រើសរើសបុគ្គលិក

ធនាគារពាណិជ្ជកម្មក្រៅប្រទេស នៃកម្ពុជា (FTB) គឺជាធនាគារពាណិជ្ជក្នុងស្រុកទី១ នៅកម្ពុជាដែលទទួលបានការទុកចិត្តចាប់តាំងពីឆ្នាំ១៩៧៩ ។ ធនាគារ FTB បានផ្តល់ជូនអតិថិជននូវសេវាហិរញ្ញវត្ថុប្រកបដោយភាពជឿទុកចិត្ត និងសុវត្ថិភាពខ្ពស់ក្នុងធុរកិច្ចរបស់ខ្លួន ។ ផ្អែកលើចក្ខុវិស័យ ជាធនាគារពាណិជ្ជដែលមានការពេញចិត្តជាងគេក្នុងព្រះរាជាណាចក្រកម្ពុជា ធនាគារ FTB ប្តេជ្ញាបន្តគាំទ្រធុរកិច្ចរបស់អតិថិជនឲ្យកាន់តែរីកចម្រើនលូតលាស់ និងផ្តល់ជូនគ្រប់បុគ្គលិកនូវឱកាសអាជីពការងារ ដែលមានស្ថិរភាពយូរអង្វែងផងដែរ ។ ធនាគារកំពុងបន្តពង្រីកនូវវិសាលភាពប្រតិបត្តិការរបស់ខ្លួន និងពង្រឹងសមត្ថភាពបុគ្គលិកដើម្បីជួយទ្រទ្រង់នូវការរីកចម្រើនប្រកបដោយចីរភាពយូរអង្វែង។ ទន្ទឹមនឹងការពង្រីកប្រតិបត្តិការនេះធនាគារយើងខ្ញុំ កំពុងស្វែងរកនូវបេក្ខភាពដែលមានគុណវុឌ្ឍិ និងឆន្ទៈខ្ពស់ ដើម្បីចូលរួមជាមួយធនាគារ FTB "**និយោជកដ៏ប្រសើរនិងឈានមុខ**" សម្រាប់មុខងារខាងក្រោម៖

## បុគ្គលិកផ្នែកគ្រប់គ្រងប្រព័ន្ធព័ត៌មានវិទ្យា (ចំនួន 0១ នាក់ បម្រើការនៅការិយាល័យកណ្តាល)

រៀបចំរបាយការណ៍ហិរញ្ញវត្ថុប្រចាំថ្ងៃ និងសប្តាហ៍តាមការកំណត់ និងចូលរួមសហការរៀបចំរបាយការណ៍ហរិញ្ញវត្ថុប្រចាំខែ និងរបាយការណ៍បន្ទាន់ផ្សេងៗ សំរាប់ថ្នាក់ដឹកនាំពិនិត្យ និងវិភាគ ។

## កិច្ចការចម្បងៗ និងការទទួលខុសត្រូវ

- រៀបចំរបាយការណ៍សាច់ប្រាក់ប្រចាំថ្ងៃ
- រៀបចំរបាយការណ៍ បំណុលនិងប្រាក់បញ្ញើ
- រៀបចំរបាយការណ៍ប្រចាំពីរសប្តាហ៍ស្តីពីប្រតិបត្តិការប្រាក់បញ្ញើ
- រៀបចំរបាយការណ៍រយៈពេលមូលដ្ឋាន និងតម្កល់ ស្តីពីប្រាក់បម្រុងកាតព្វកិច្ច
- ទំនាក់ទំនងល្អជាមួយធនាគារជាតិ នៃកម្ពុជា អំពីកំណែទម្រង់លើរបាយការណ៍ហិរញ្ញវត្ថុឲ្យបានល្អ ប្រសើរក្នុងន័យសហប្រតិបត្តិការល្អជាមួយគ្នា ។
- បញ្ជូនរបាយការណ៍សម្រាប់បញ្ចូលក្នុងប្រព័ន្ធ VPN របស់ធនាគារជាតិ ។
- សិក្សា និងអនុវត្តឲ្យកាន់តែប្រសើរនូវការងារថ្មីៗ ដោយស្វែងរកគន្លឹះងាយស្រួល ឆាប់រហ័សជាមួយនឹងភាពត្រឹមត្រូវ លើការតំឡើងរបាយការណ៍នានា ។
- គោរពតាមគោលការណ៍ សេចក្តីណែនាំ និងនិតិវិធីរបស់ធនាគារអោយមានប្រសិទ្ធភាពខ្ពស់ ។
- ការទទួលខុសត្រូវផ្សេងៗទៀត ទៅតាមការចាត់តាំងរបស់ថ្នាក់គ្រប់គ្រង ។

## ជំនាញ និងបទពិសោធន៍

- បរិញ្ញបត្រផ្នែកធនាគារ និងហិរញ្ញវត្ថុ ផ្នែកសេដ្ឋកិច្ច ឬផ្នែកនានាដែលពាក់ព័ន្ធ ។
- មានបទពិសោធន៍យ៉ាងតិច១ឆ្នាំ បម្រើការងារក្នុងវិស័យធនាគារ ឬមីក្រូហិរញ្ញវត្ថុ ខាងផ្នែករៀបចំរបាយការណ៍
- មានជំនាញវិជ្ជាជីវៈ និងចេះគ្រប់គ្រងពេលវេលាបានល្អ
- មានគំនិតច្នៃប្រឌិត អាចធ្វើការងារជាក្រុម មានការសហការល្អ និងចេះបត់បែនក្នុងការងារ
- មានចំណេះដឹងផ្នែកភាសាអង់គ្លេសល្អ
- អាចប្រើប្រាស់កុំព្យូទ័របានស្ទាត់ជំនាញ (Microsoft Office Word & Excel)

## របៀបដាក់ពាក្យ

កាលបរិច្ឆេទកំណត់ដាក់ពាក្យៈ ផុតកំណត់ឈប់ទទួលពាក្យនៅថ្ងៃទី **១០** ខែ **កុម្ភៈ** ឆ្នាំ **២០២១** វេលាម៉ោង ០៥:00 ល្ងាច ។

បេក្ខជនដែលមានចំណាប់អារម្មណ៍ សូមអញ្ជើញផ្ញើប្រវត្តិរូបសង្ខេប (<u>មានបិទរូបថត 4x6</u>) ជាមួយលិខិតអមជាភាសាខ្មែរ/អង់គ្លេសមកធនាគារតាមរយៈអ៊ីម៉ែលៈ **hr@ftbbank.com** ឬការិយាល័យកណ្តាល ស្ថិតនៅអគារលេខ ៣៣C-D ផ្លូវលេខ ១៦៩ សង្កាត់វាលវង់ ខណ្ឌ៧មករា រាជធានីភ្នំពេញ ឬតាមសាខាណាមួយ របស់ធនាគារពាណិជ្ជកម្មក្រៅប្រទេស នៃកម្ពុជា ។ មានតែបេក្ខជនដែលមានលក្ខណៈសម្បត្តិគ្រប់គ្រាន់នឹងត្រូវបានជាប់ក្នុងបញ្ជីសម្រាំង និងត្រូវបានទូរស័ព្ទអញ្ជើញឲ្យមកចូលសម្ភាសន៍ ។

ព័ត៌មានបន្ថែមសូមទំនាក់ទំនងមកកាន់លេខទូរសព្ទ: ០៨១ ៦៦៦ ៥៩៧ / ០៨១ ៦៦៦ ៥៣៥

វិនិយោគដើម្បីអនាគត
Investing in the future

☎ : 023 862 111
E-mail: hr@ftbbank.com
www.ftbbank.com
f : www.facebook.com/ftbcambodia